ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្ដីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកុម្ភៈ និងទិសដៅការងារខែមីនា ឆ្នាំ២០២៦

នៅក្នុងខែកុម្ភៈ ឆ្នាំ២០២៦ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានផ្ដល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

## I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥

### ១-មុខងារនីតិកម្ម

- សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និងជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ (ក.ជ.ប.ព) លើកទី៦ និងលើកទី៧ អាណត្តិទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ប្រធាន (ក.ជ.ប.ព) នៅអង្គភាពប្រឆាំងអំពើពុករលួយ។

### ២-មុខងារតាមដានការអនុវត្តច្បាប់

- **បានរៀបចំចាត់ចែង និងផ្ដល់សេវាជូនគណៈកម្មការនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបំពេញបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តនានា៖**

❖ គណៈកម្មការទី១ព្រឹទ្ធសភា បានចុះបំពេញបេសកកម្ម ដើម្បីជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល ដើម្បីឈ្វេងយល់ និងប្រមូលព័ត៌មាន ពីការអនុវត្តការងារ និងបញ្ហាប្រឈមនានា និងជួបពិភាក្សាការងារជាមួយមន្ត្រីពន្ធនាគារ ដើម្បីឈ្វេងយល់ពីស្ថានភាពអ្នកជាប់ឃុំ (ពិរុទ្ធជន និងទណ្ឌិត) ការលំបាក សំណូមពរ និងជួបផ្លាស់ប្ដូរយោបល់ជាមួយគណៈអភិបាលខេត្តកែប ខេត្តកំពត និងខេត្តព្រះសីហនុ។

❖ គណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយ **ឯកឧត្តម អ៊ាង សុផល្លែត** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ដើម្បីឈ្វេងយល់ពីវឌ្ឍនភាពការងារ បញ្ហាប្រឈមនានា ក្នុងឆ្នាំ២០២៥

និងទិសដៅការងាររបស់ក្រសួងសម្រាប់ឆ្នាំ២០២៦ នៅក្រសួងបរិស្ថាន។

❖ គណៈកម្មការទី១០ព្រឹទ្ធសភា៖

- បានអញ្ជើញចុះបំពេញបេសកកម្ម និងនាំយកអំណោយមនុស្សធម៌របស់ព្រឹទ្ធសភា និងមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ ប្រគល់ជូនរដ្ឋបាលខេត្តសៀមរាប និង
- បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់អំពីប្រសិទ្ធភាព និងបញ្ហាប្រឈមនានានៃការអនុវត្តច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយ និងការអភិវឌ្ឍមូលដ្ឋាន នៅខេត្តស្វាយរៀង។

## ៣-មុខងារតំណាង

**- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា រួមមាន៖**

**❖ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា៖**

- **សកម្មភាពចូលរួមពិធីផ្សេងៗ៖**
  - បានអញ្ជើញបន្តតាមដានដោយយកចិត្តទុកដាក់ខ្ពស់ចំពោះការវិវត្តសភាពការណ៍ នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ និង
  - បានអញ្ជើញដង្ហែព្រះរាជដំណើរ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ព្រះអង្គយាងទៅពិនិត្យព្រះរាជសុខភាព នៅសាធារណរដ្ឋប្រជាមានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិតេជោ ខេត្តកណ្តាល។

**❖ ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា៖**

- **សកម្មភាពដឹកនាំកិច្ចប្រជុំ៖** អញ្ជើញដឹកនាំកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភា ប្រចាំភូមិភាគទី២ នៅវិមានព្រឹទ្ធសភា ដែលមានរបៀបវារៈ
  - ពិនិត្យលើសេចក្តីព្រាងកម្មវិធីលម្អិតសម្រាប់ចុះសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់។
  - គម្រោងចំណាយ និង
  - ផ្សេងៗ។
- **បេសកកម្មក្នុងប្រទេស៖**
  - បានអញ្ជើញចុះជួបសំណេះសំណាល ផ្សព្វផ្សាយសភាពការណ៍កម្ពុជា និងសមិទ្ធផលនានា ជូនដល់ក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីរាជការ និងប្រជាពលរដ្ឋ នៅក្នុងក្រុង និងស្រុកទូទាំងខេត្តត្បូងឃ្មុំ ព្រមទាំងបានអញ្ជើញសួរសុខទុក្ខ និងផ្តល់អំណោយ និងថវិកាមួយចំនួនជូនដល់វីរកងទ័ព ដែលកំពុងសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យបង្អែកស្រុកបាធាយ ខេត្តកំពង់ចាម។

- បានចាត់តាំង **ឯកឧត្តម នេត សេរី** ទីប្រឹក្សារបស់ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា និងមន្ត្រីខុទ្ទកាល័យ អញ្ជើញចុះពិនិត្យ និងទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីត្រៀមរៀបចំកម្មវិធីពិនិត្យ និងព្យាបាលជំងឺជូនបងប្អូនភៀសសឹកដោយឥតគិតថ្លៃ នៅសាលាបឋមសិក្សាស្ពាង ឃុំត្រពាំងគរ ស្រុកជើងព្រៃ ខេត្តកំពង់ចាម មណ្ឌលជនភៀសសឹកវត្តប្រាសាទធ្នង់ ស្រុកអង្គរជុំ និងវត្តជ្រោយនាងនួន ស្រុកស្រីស្នំ ខេត្តសៀមរាប និង
- បានអញ្ជើញចុះសួរសុខទុក្ខវីរកងទ័ពជួរមុខ នៅខេត្តព្រះវិហារ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ និងខេត្តពោធិ៍សាត់។

▪ **សកម្មភាពចូលរួមពិធីផ្សេងៗ៖** បានអញ្ជើញចូលរួមដង្ហែ ព្រះរាជដំណើររបស់ **ព្រះករុណាជាអម្ចាស់ ជីវិតលើត្បូង និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ ស្តេចយាងទៅពិនិត្យព្រះរាជសុខភាព នៅរាជធានីប៉េកាំងនៃសាធារណរដ្ឋប្រជាមានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិតេជោ ខេត្តកណ្តាល។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ខន្សោ អនុប្រធានទី២ព្រឹទ្ធសភា៖**

▪ **សកម្មភាពដឹកនាំកិច្ចប្រជុំ៖**

- បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា និង
- បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំជាមួយទីប្រឹក្សា ថ្នាក់ដឹកនាំ និងសមាជិកខុទ្ទកាល័យប្រចាំខែកុម្ភៈ និងកំណត់ទិសដៅការងារខែមីនា ឆ្នាំ២០២៦ នៅសាលប្រជុំខុទ្ទកាល័យ។

▪ **សកម្មភាពចុះមូលដ្ឋាន៖**

- បានអញ្ជើញជាអធិបតីក្នុងពិធីសំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាសង្កាត់ អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធសរុប មកពីទូទាំងសង្កាត់នៃខណ្ឌទួលគោក ខណ្ឌឫស្សីកែវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
- បានអញ្ជើញជួបសំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាសង្កាត់សុខដុម ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី និង
- បានអញ្ជើញទស្សនកិច្ចនៅចម្ការកាកាវ **លោកឧកញ៉ា ហៃ លីអ៊ាង** នៅខេត្តរតនគិរី និងទស្សនកិច្ចនៅចម្ការកាហ្វេ ភីដា (PIDA Coffee Farm) ដែលជាគំរូនៃជោគជ័យក្នុងវិស័យកាហ្វេ នៅខេត្តមណ្ឌលគិរី។

▪ **សកម្មភាពចូលរួមពិធីផ្សេងៗ៖**

- បានអញ្ជើញធ្វើបទបាឋកថាស្តីពី "ដំណើរឆ្ពោះទៅការផលិតទំនិញនៅកម្ពុជា" ដល់សាស្ត្រាចារ្យ និងនិស្សិត ចំនួន៣០០នាក់ នៃសាកលវិទ្យាល័យជាតិ ជា ស៊ីម កំចាយមារ ខេត្តព្រៃវែង។
- បានអញ្ជើញដឹកនាំគណៈប្រតិភូក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ចូលរួមពិធីបុណ្យគម្រប់៧ថ្ងៃ **ឯកឧត្តម ក្រូច ផាន** អតីតប្រធានក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ

និងជាអតីតជំនួយការផ្ទាល់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៅរាជធានីភ្នំពេញ និង

- បានអញ្ជើញសួរសុខទុក្ខ **ឯកឧត្តមបណ្ឌិត អ៊ុម រម្យណី** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និងជាអតីតនាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC) ដែលកំពុងសម្រាកព្យាបាលជំងឺ នៅមន្ទីរពេទ្យកាល់ម៉ែត រាជធានីភ្នំពេញ។

❖ **សមាជិក សមាជិកាព្រឹទ្ធសភា៖**

- បានអញ្ជើញចូលរួមពិធីក្រុងពាលី និងចម្រើនព្រះបរិត្តឡើងអគារថ្មី វិមានសាមគ្គីភាព ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** នៅវិមានសាមគ្គីភាព។
- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបញ្ចុះបឋមសិលាសាងសង់អគារមន្ទីរពេទ្យសម្រាប់វះកាត់ និងសង្គ្រោះបន្ទាន់ ចំនួន២ខ្នង ដែលជាអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចក្រឡាហោម ស ខេង** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និង**លោកជំទាវ** ក្រោមអធិបតីភាព **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង **លោកជំទាវ** នៅខេត្តព្រៃវែង។
- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបុណ្យមាឃបូជា ក្រោមអធិបតីភាពរបស់ **ឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន** ឧបនាយករដ្ឋមន្ត្រី និង**លោកជំទាវ** នៅបរិវេណឧបដ្ឋានសាលាមុខព្រះមហាសក្យមុនីចេតិយ ភ្នំព្រះរាជទ្រព្យ ស្រុកពញាឮ ខេត្តកណ្តាល។
- បានអញ្ជើញចូលរួមប្រជុំដើម្បីពិនិត្យរបាយការណ៍បូកសរុបលទ្ធផលនៃការចុះជួបប្រជុំជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី នៅសាលប្រជុំសាលាខេត្តមណ្ឌលគិរី។
- បានអញ្ជើញធ្វើបទបង្ហាញស្តីពី រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា ជូននិស្សិតនៃវិទ្យាស្ថានវ៉ាន់ដា មកទស្សនកិច្ចសិក្សាឈ្វេងយល់អំពីព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
- បានអញ្ជើញចូលរួមជាកិត្តិយសផ្តល់បាឋកថា និងមតិបូកសរុប ក្នុងវគ្គបណ្តុះបណ្តាលស្តីពី វិធីសាស្ត្រស្រាវជ្រាវ ការងារ និងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានបញ្ញាសិប្បនិម្មិតក្នុងការរៀបចំសុន្ទរកថា បទអន្តរាគមន៍ សេចក្តីថ្លែងការណ៍ និងសេចក្តីប្រកាសព័ត៌មាន នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា និង

- ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាលសាកសួរសុខទុក្ខប្រជាពលរដ្ឋ និងជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀននាយប៉ុស្តិ៍នគរបាលរដ្ឋបាល ប្រធានមណ្ឌលសុខភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥ នៅមូលដ្ឋាន និងឈ្វេងយល់អំពីវឌ្ឍនភាពការងារ សន្តិសុខ សណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានី

ភ្នំពេញ និងតាមបណ្ដាខេត្តនានា **ចំនួន១៣៩លើក** ព្រមទាំងបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធផលនានា និងពិធីផ្លូវការផ្សេងៗ **ចំនួន១៦០លើក**។

- **សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ ឯកឧត្តម ឡោក ឆាយ** និង**ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគមបេសកកម្មមនុស្សធម៌នៅកម្ពុជា របស់សាធារណរដ្ឋបារាំង ចុះជួបសំណេះសំណាល សាកសួរសុខទុក្ខ និងពិនិត្យព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋ នៅភូមិក្ដីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា៖

- បានអមដំណើរ **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា អញ្ជើញចុះសួរសុខទុក្ខវីរកងទ័ពជួរមុខ នៅខេត្តព្រះវិហារ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ និងខេត្តពោធិ៍សាត់។
- បានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកថវិការបស់ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា ជូនអាជ្ញាធរសង្កាត់ព្រែកតាសេក និងបានឧបត្ថម្ភថវិកា ជូនបងប្អូនប្រជាពលរដ្ឋសាសនិកឥស្លាម សម្រាប់ស្រាយបួសក្នុងពិធីបុណ្យរ៉ាម៉ាឌន នៅសង្កាត់ព្រែកតាសេក និង
- បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងចូលរួមពិធីផ្សេងៗ ចំនួន៦លើក។

❖ **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងចូលរួមពិធីផ្សេងៗ ចំនួន៣លើក។

❖ **ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងចូលរួមពិធីផ្សេងៗ ចំនួន៥លើក និង

❖ **ឯកឧត្តម ឌី បញ្ញា** អគ្គលេខាធិការរងព្រឹទ្ធសភា៖

- បានអញ្ជើញចូលរួមស្ដាប់បាឋកថាឧទ្ទេសនាមដោយ **ឯកឧត្តម កែវ ពង្ស** ទីប្រឹក្សាផ្ទាល់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អំពីប្រវត្តិតស៊ូ ខ្សែជីវិត ដែលបានឆ្លងកាត់ដោយផ្ទាល់ក្នុងដំណើរការនៃការចាប់ផ្ដើមអនុវត្តនយោបាយឈ្នះ ឈ្នះ បង្រួបបង្រួមជាតិរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្នុងបុព្វហេតុដើម្បីប្រទេសជាតិ និងប្រជាជន នៅវិមាន៧មករា និង
- បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន២លើក។

- បានរៀបចំគ្រឿងសក្ការបូជាសម្រាប់រាប់បាត្រប្រគេនព្រះសង្ឃក្នុងពិធីបុណ្យមាឃបូជា ចំនួន៨០កញ្ចប់ និង

- បានទទួលពាក្យបណ្តឹង ចំនួន៤បណ្តឹង បញ្ជូនពាក្យបណ្តឹងចេញទៅក្រសួង ខេត្ត និងស្ថាប័នពាក់ព័ន្ធ ចំនួន៣បណ្តឹង កំពុងពិនិត្យសិក្សា ចំនួន១១បណ្តឹង ធ្វើកំណត់បង្ហាញគោរពរាយការណ៍ ជូនសម្តេចតេជោប្រធានព្រឹទ្ធសភា ពីលទ្ធផលនៃការដោះស្រាយពាក្យបណ្តឹង របស់គណៈកម្មការ ចំនួន២បណ្តឹង ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធ ចំនួន២បណ្តឹង និង ទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ចំនួន៤បណ្តឹង។

## ៤-មុខងារសហប្រតិបត្តិការអន្តរជាតិ

- **បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា រួមមាន៖**

❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា៖**

- **សកម្មភាពចូលរួមកិច្ចប្រជុំ៖** បានអញ្ជើញចូលរួមកិច្ចប្រជុំកំពូលថ្នាក់ដឹកនាំនៃគណបក្សទាំង៣ ជាមួយនឹង **ឯកឧត្តម** To Lam អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម និង **ឯកឧត្តមបណ្ឌិត** Thongloun Sisoulith អគ្គលេខាធិការបក្សប្រជាជនបដិវត្តន៍ឡាវ នៅវិមាន៧មករា។
- **បដិសណ្ឋារកិច្ចភ្ញៀវជាតិ-អន្តរជាតិ៖** បានអនុញ្ញាតឱ្យភ្ញៀវជាតិ-អន្តរជាតិ ចូលជួប សំណេះសំណាល សួរសុខទុក្ខ ពិភាក្សាការងារ និងសម្តែងការគួរសម ចំនួន៦លើក នៅព្រះបរមរាជវាំង និងវិមានសាមគ្គីភាព រួមមាន៖
  + ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ **ព្រះករុណា ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា៖
    - ទទួលបដិសណ្ឋារកិច្ចស្វាគមន៍ ជួបសវនាការផ្លូវរដ្ឋ រៀបចំពិធីលៀងសាយភោជន៍ផ្លូវរដ្ឋ និងពិធីលៀងភោជនាហារផ្លូវរដ្ឋជាកិត្តិយសជូន **ឯកឧត្តម** To Lam អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម និង**ឯកឧត្តមបណ្ឌិត** Thongloun Sisoulith អគ្គលេខាធិការបក្សប្រជាជនបដិវត្តន៍ឡាវ និងជាប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្នុងឱកាសដែល **ឯកឧត្តម** និងគណៈប្រតិភូជាន់ខ្ពស់ អញ្ជើញមកបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា។
  + ក្នុងនាមជាប្រធានព្រឹទ្ធសភាបានទទួលជួប៖
    - **ឯកឧត្តម** Syed Yusuf Raza Gillani ប្រធានព្រឹទ្ធសភានៃសាធារណរដ្ឋឥស្លាមប៉ាគីស្ថាន និងជាប្រធានស្ថាបនិកនៃសន្និសីទប្រធានសភានៃអន្តរសភា (ISC)។
    - **ឯកឧត្តម** Saichay Kommasith អនុរដ្ឋមន្ត្រីក្រសួងការពារប្រទេសនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។
    - **ឯកឧត្តម** Thomas Lam ប្រធានក្រុមមិត្តភាពរដ្ឋសភាបារាំង-កម្ពុជា និង
    - ប្រជាពលរដ្ឋខ្មែរ ដែលជាយុវជនគណបក្សប្រជាជនកម្ពុជា នៅក្នុងរដ្ឋនានា នៅតំបន់ឆ្នេរខាងលិចនៃសហរដ្ឋអាមេរិក។

- **សកម្មភាពចូលរួមពិធីផ្សេងៗ៖**
  - បានអញ្ជើញជាអធិបតីជាមួយនឹង **ឯកឧត្តម** Syed Yusuf Raza Gillani ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពី "ការពង្រឹងកិច្ចសហប្រតិបត្តិការកិច្ចការសភា" រវាង **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និង**ឯកឧត្តម** Zaheeruddin Babar Thaheem ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥស្លាមប៉ាគីស្ថាន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា តំណាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប៉ាគីស្ថាន នៅវិមានសាមគ្គីភាព។
  - បានអញ្ជើញជាអធិបតីជាមួយ **ឯកឧត្តម** To Lam អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងគណៈទាក់ទងការបរទេស គណបក្សប្រជាជនកម្ពុជា និងគណៈកម្មាធិការបក្សក្រសួងការបរទេសវៀតណាម នៅវិមាន៧មករា និងពិធីបញ្ចុះបឋមសិលាសាងសង់សាលាមិត្តភាពកម្ពុជា-វៀតណាម នៅខណ្ឌដង្កោ រាជធានីភ្នំពេញ។
  - បានអញ្ជើញចូលរួមពិធីចុះហត្ថលេខាលើកំណត់ហេតុកិច្ចប្រជុំកំពូលលើកទី១៦ រវាងគណបក្សទាំងពីរ ជាមួយ **ឯកឧត្តមបណ្ឌិត** Thongloun Sisoulith អគ្គលេខាធិការបក្សប្រជាជនបដិវត្តន៍ឡាវ និងជាប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅវិមានសាមគ្គីភាព។
  - បានអញ្ជើញរៀបចំពិធីលៀងសាយភោជន៍ផ្លូវការ និងពិសាអាហារពេលព្រឹក ជាមួយ **ឯកឧត្តម** Syed Yusuf Raza Gillani ប្រធានព្រឹទ្ធសភានៃសាធារណរដ្ឋឥស្លាមប៉ាគីស្ថាន នៅវិមានសាមគ្គីភាព និងសណ្ឋាគារហៃយ៉ាត់រីជេនស៊ី ភ្នំពេញ និង
  - បានអញ្ជើញរៀបចំពិធីអាហារថ្ងៃត្រង់ទទួលស្វាគមន៍ **ឯកឧត្តម** To Lam អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម និង**ឯកឧត្តមបណ្ឌិត** Thongloun Sisoulith អគ្គលេខាធិការបក្សប្រជាជនបដិវត្តន៍ឡាវ និងគណៈប្រតិភូគណបក្សទាំង៣ នៅវិមាន៧មករា។

❖ **ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា៖**

- **សកម្មភាពដឹកនាំកិច្ចប្រជុំ៖**
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាលើការរៀបចំកិច្ចប្រជុំគណៈកម្មការនយោបាយនៃសភាប្រេីភាសាបារាំង (APF) ឆ្នាំ២០២៦ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា និង
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំត្រៀមរៀបចំសន្និសីទប្រធានសភានៃអន្តរជាតិ (ISC) លើកទី២ នៅវិមានព្រឹទ្ធសភា។
- **បដិសណ្ឋារកិច្ចភ្ញៀវអន្តរជាតិ៖** បានអនុញ្ញាតឱ្យភ្ញៀវអន្តរជាតិ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ចំនួន២លើក នៅវិមានសាមគ្គីភាព រួមមាន៖
  - **ឯកឧត្តម** Thomas LAM សមាជិកនៃរដ្ឋសភាបារាំង និងជាប្រធានក្រុមមិត្តភាពរដ្ឋសភាបារាំង-កម្ពុជា និង

- **ឯកឧត្តម** Park Joo Bong ប្រធានសភាពាណិជ្ជកម្ម និងឧស្សាហកម្មរបស់ទីក្រុង Incheon និងជាអគ្គនាយកក្រុមហ៊ុន Daejoo KC Group និងជាទីប្រឹក្សាឯកឧត្តម អនុប្រធានទី១ព្រឹទ្ធសភា។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ខឿន្យនា អនុប្រធានទី២ព្រឹទ្ធសភា៖**

- **បដិសណ្ឋារកិច្ចភ្ញៀវអន្តរជាតិ៖** បានអញ្ជើញទទួលបដិសណ្ឋារកិច្ចស្វាគមន៍ និងជូនដំណើរមាតុភូមិនិវត្តន៍ និងអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ជួបទ្វេភាគីជាមួយ **ឯកឧត្តម** Syed Yusuf Raza Gillani ប្រធានព្រឹទ្ធសភានៃសាធារណរដ្ឋឥស្លាមប៉ាគីស្ថាន និងជាប្រធានស្ថាបនិកនៃសន្និសីទប្រធានសភានៃអន្តរសភា (ISC) ក្នុងឱកាសបំពេញទស្សនកិច្ចផ្លូវការ នៅព្រះរាជាណាចក្រកម្ពុជា នៅវិមានសាមគ្គីភាព។
- **សកម្មភាពចូលរួមពិធីផ្សេងៗ៖**
  - បានអញ្ជើញអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា រៀបចំពិធីជប់លៀងសាយភោជន៍ជាកិត្តិយសជូនប្រធានព្រឹទ្ធសភានៃសាធារណរដ្ឋឥស្លាមប៉ាគីស្ថាន និងគណៈប្រតិភូ នៅវិមានសាមគ្គីភាព។
  - បានអញ្ជើញអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្នុងព្រះបរមនាម **ព្រះករុណា ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា រៀបចំពិធីលៀងសាយភោជន៍ផ្លូវរដ្ឋជូន **ឯកឧត្តម** To Lam អគ្គលេខាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម នៅវិមានសាមគ្គីភាព។
  - បានអញ្ជើញអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្នុងព្រះបរមនាម **ព្រះករុណា ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា រៀបចំពិធីលៀងភោជនាហារផ្លូវរដ្ឋជាកិត្តិយសជូន **ឯកឧត្តមបណ្ឌិត** Thongloun Sisoulith អគ្គលេខាធិការបក្សប្រជាជនបដិវត្តន៍ឡាវ និងជាប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅវិមានសាមគ្គីភាព និង
  - បានអញ្ជើញចូលរួមពិធីចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពី "ការពង្រឹងកិច្ចសហប្រតិបត្តិការកិច្ចការសភា" រវាងអគ្គលេខាធិការព្រឹទ្ធសភាកម្ពុជា និងឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥស្លាមប៉ាគីស្ថាន ប្រចាំព្រះរាជាណាចក្រកម្ពុជា តំណាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប៉ាគីស្ថាន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងប្រធានព្រឹទ្ធសភានៃសាធារណរដ្ឋឥស្លាមប៉ាគីស្ថាន នៅវិមានសាមគ្គីភាព។

❖ **ឯកឧត្តម ងី ច័ន្ទ្រផល** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា៖

- បានអញ្ជើញអមដំណើរ **ឯកឧត្តម** Syed Yusuf Raza Gillani ប្រធានព្រឹទ្ធសភានៃសាធារណរដ្ឋឥស្លាមប៉ាគីស្ថាន ចូលក្រាបបង្គំគាល់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅព្រះបរមរាជវាំង។

- បានអញ្ជើញចូលរួមក្នុងជំនួបទ្វេភាគីរវាង **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ជាមួយ **ឯកឧត្តម** Syed Yusuf Raza Gillani ប្រធានព្រឹទ្ធសភានៃសាធារណរដ្ឋឥស្លាមប៉ាគីស្ថាន និងជាប្រធានស្ថាបនិកនៃសន្និសីទប្រធានសភានៃអន្តរសភា (ISC) នៅវិមានសាមគ្គីភាព។
- បានអញ្ជើញអមដំណើរ **ឯកឧត្តម** Syed Yusuf Raza Gillani ប្រធានព្រឹទ្ធសភានៃសាធារណរដ្ឋឥស្លាមប៉ាគីស្ថាន ចូលជួបសម្តែងការគួរសមជាមួយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានសន្តិភាព និង**សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា នៅវិមានរដ្ឋសភា និង
- បានអញ្ជើញជួបជាមួយ **ឯកឧត្តម ឯកណាត ជាកាល់** អគ្គលេខាធិការនៃសន្និសីទប្រធានសភានៃអន្តរសភា(ISC) ដើម្បីពិភាក្សាការងារពាក់ព័ន្ធនឹងការត្រៀមរៀបចំសន្និសីទប្រធានសភានៃអន្តរសភា (ISC) នៅសណ្ឋាគារហៃយ៉ាត់ រីជិនស៊ី រាជធានីភ្នំពេញ។

❖ **ឯកឧត្តម យស ផានីត្តា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិ និងមហាសន្និបាតលើកទី១៦នៃសភាតំបន់អាស៊ី(APA) នៅទីក្រុងម៉ាណាម៉ា ព្រះរាជាណាចក្របារ៉ែន។

❖ **ឯកឧត្តមបណ្ឌិត ឈីវ យីស៊ាង** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា៖

- បានអញ្ជើញទទួលជួប និងពិភាក្សាការងារជាមួយ **លោកជំទាវ** Milena Caridad Zaldivar Piedra ឯកអគ្គរដ្ឋទូតគុយបា ប្រចាំព្រះរាជាណាចក្រកម្ពុជា និង
- បានអញ្ជើញចូលរួមក្នុងពិធីទទួលទានភោជនាហារពេលល្ងាច ដើម្បីអបអរសាទរ "ទិវាជាតិអូស្ត្រាលី ឆ្នាំ២០២៦" នៅស្ថានទូតអូស្ត្រាលី។

❖ **ឯកឧត្តម ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយ **ឯកឧត្តម** Florian TILLY នាយកប្រតិបត្តិអន្តរជាតិនៃមូលនិធិមហាឫស្សី ដើម្បីសន្តិភាពពិភពលោក ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។

❖ **ឯកឧត្តម អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការត្រួតពិនិត្យ និងតាមដានប្រជាធិបតេយ្យនៃសភាប្រើភាសាបារាំង(APF) នៅទីក្រុងប៉ូដហ្គោរីកា សាធារណរដ្ឋម៉ុងតេណេហ្គ្រោ។

❖ **ឯកឧត្តម ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា **ឯកឧត្តមបណ្ឌិត ឈីវ យីស៊ាង** ប្រធានគណៈកម្មការទី៥ និង**ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញជាកិត្តិយសក្នុងពិធីអបអរសាទរពិធីចម្រើនព្រះជន្មគម្រប់ ៦៦ព្រះវស្សា របស់ **ព្រះករុណាព្រះចៅអធិរាជជប៉ុន ណារុហ៊ីតុ** និងមិត្តភាពដ៏យូរអង្វែងរវាងជប៉ុន និងកម្ពុជា នៅស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា រាជធានីភ្នំពេញ។

❖ **សម្តេចព្រះរាជបុត្រីព្រះអនុជ នរោត្តម អរុណរស្មី** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភា៖

- បានសព្វព្រះហឫទ័យអនុញ្ញាតជូន **ឯកឧត្តម** Santo Darmosumarto ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥណ្ឌូណេស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា និង**លោកជំទាវ** ចូលជួបថ្វាយបង្គំលាក្នុងឱកាសដែលឯកឧត្តមឯកអគ្គរដ្ឋទូត បានបញ្ចប់បេសកកម្មការទូត នៅព្រះរាជាណាចក្រកម្ពុជា និង
- បានសព្វព្រះហឫទ័យទទួលជួប និងលៀងអាហារថ្ងៃត្រង់ជូនដំណើរ **លោកជំទាវ** Teo Lay Cheng ឯកអគ្គរដ្ឋទូតនៃប្រទេសសិង្ហបុរី ប្រចាំព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសដែលលោកជំទាវឯកអគ្គរដ្ឋទូត បានបញ្ចប់បេសកកម្មការទូត នៅព្រះរាជាណាចក្រកម្ពុជាប្រកបដោយជោគជ័យ។

❖ សមាជិក សមាជិកាព្រឹទ្ធសភា៖

- បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមសភាជាតិកម្ពុជា(APF) ពិភាក្សាលើការរៀបចំកិច្ចប្រជុំគណៈកម្មការនយោបាយនៃសភាប្រើភាសាបារាំង ឆ្នាំ២០២៦ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា និង
- បានអញ្ជើញចូលរួមក្នុងពិធីលៀងសាយភោជន៍ផ្លូវរដ្ឋជូន **ឯកឧត្តម** To Lam អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម និងពិធីលៀងភោជនាហារផ្លូវរដ្ឋជូន **ឯកឧត្តមបណ្ឌិត** Thongloun Sisoulith អគ្គលេខាធិការបក្សប្រជាជនបដិវត្តន៍ឡាវ និងជាប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ រៀបចំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៅវិមានសាមគ្គីភាព។

- **សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា៖

- បានអញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ **ព្រះករុណា ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា៖ ទទួលបដិសណ្ឋារកិច្ចស្វាគមន៍ រៀបចំពិធីលៀងសាយភោជន៍ផ្លូវរដ្ឋ និងពិធីលៀងភោជនាហារផ្លូវរដ្ឋជាកិត្តិយសជូន **ឯកឧត្តម** To Lam អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម និង **ឯកឧត្តមបណ្ឌិត** Thongloun Sisoulith អគ្គលេខាធិការបក្សប្រជាជនបដិវត្តន៍ឡាវ និងជាប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្នុងឱកាសដែល **ឯកឧត្តម** និងគណៈប្រតិភូជាន់ខ្ពស់ អញ្ជើញមកបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា។
- បានអញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្នុងជំនួបទ្វេភាគី ពិភាក្សាការងារ និងសម្តែងការគួរសម ជាមួយភ្ញៀវអន្តរជាតិ នៅវិមានសាមគ្គីភាព ចំនួន៣លើក និងតាមប្រព័ន្ធនិម្មិត ចំនួន១លើក។
- បានអញ្ជើញទទួលស្វាគមន៍ និងជូនកន្ត្រកផ្កាដល់ **ឯកឧត្តម** Syed Yusuf Raza Gillani ប្រធានព្រឹទ្ធសភានៃសាធារណរដ្ឋឥស្លាមប៉ាគីស្ថាន និងជាប្រធានស្ថាបនិកនៃសន្និសីទ

ប្រធានសភានៃអន្តរសភា ISC នៅសណ្ឋាគារហៃយ៉ាត់ រីជិនស៊ី រាជធានីភ្នំពេញ។

- បានអញ្ជើញចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពី "ការពង្រឹងកិច្ចសហប្រតិបត្តិការកិច្ចការសភា" រវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប៉ាគីស្ថាន តំណាងដោយ **ឯកឧត្តម Zaheeruddin Babar Thaheem** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥស្លាមប៉ាគីស្ថាន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង**ឯកឧត្តម Syed Yusuf Raza Gillani** ប្រធានព្រឹទ្ធសភានៃសាធារណរដ្ឋឥស្លាមប៉ាគីស្ថាន។
- បានអញ្ជើញចូលរួមកិច្ចប្រជុំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា អញ្ជើញដឹកនាំកិច្ចប្រជុំត្រៀមរៀបចំសន្និសីទ ISC លើកទី២ នៅសាលប្រជុំឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា និង
- អញ្ជើញចូលរួមកម្មវិធីអបអរសាទរព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់ ៦៦ព្រះវស្សា របស់ព្រះចៅអធិរាជជប៉ុន Naruhito នៅនិវេសនដ្ឋានផ្លូវការរបស់ឯកអគ្គរដ្ឋទូតជប៉ុន ក្នុងរាជធានីភ្នំពេញ។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីលៀងសាយភោជន៍ផ្លូវរដ្ឋជូន **ឯកឧត្តម To Lam** អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម និងចូលរួមពិធីលៀងភោជនាហារផ្លូវរដ្ឋជាកិត្តិយសជូន **ឯកឧត្តមបណ្ឌិត Thongloun Sisoulith** អគ្គលេខាធិការបក្សប្រជាជនបដិវត្តន៍ឡាវ និងជាប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ រៀបចំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ **ព្រះករុណា ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានសាមគ្គីភាព។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម អោក ប៉ូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមប្រជុំជាមួយគណៈបញ្ជាការ ការពារសន្តិសុខគោលដៅវិមានព្រឹទ្ធសភា ដើម្បីត្រៀមរៀបចំផែនការការពារ និងទទួលឯកឧត្តមប្រធានព្រឹទ្ធសភានៃសាធារណរដ្ឋឥស្លាមប៉ាគីស្ថាន និងលោកជំទាវ ដឹកនាំដោយ **ឯកឧត្តមនាយឧត្តមសេនីយ៍សន្តិបណ្ឌិត យូ ស៊ុនឡុង** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នៅនាយកដ្ឋានអង្គរក្ស។

❖ **ឯកឧត្តម ឡោក ឆាយ** និង**ឯកឧត្តម អោក ប៉ូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញទទួលដំណើរ **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា អញ្ជើញដឹកនាំគណៈប្រតិភូសភាកម្ពុជា ធ្វើមាតុភូមិនិវត្តន៍មកកាន់ប្រទេសវិញ នៅអាកាសយានដ្ឋានអន្តរជាតិតេជោ ខេត្តកណ្តាល។

❖ **ឯកឧត្តម ឌី បញ្ញា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្នុងជំនួបទ្វេភាគី ពិភាក្សាការងារ និងសម្តែងការគួរសមជាមួយភ្ញៀវជាតិ-អន្តរជាតិ នៅវិមានសាមគ្គីភាព ចំនួន៤លើក។

- បានសហការ និងទាក់ទងជាមួយមជ្ឈមណ្ឌលឯកសារច្បាប់កម្ពុជា សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន មូលនិធិចិនដើម្បីអភិវឌ្ឍន៍ជនបទ (CFRD) សាកលវិទ្យាល័យអាស៊ីអឺរ៉ុប មជ្ឈមណ្ឌលកម្ពុជា-សិង្ហបុរី បណ្ណសារដ្ឋានជាតិ-អន្តរជាតិ និងក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ក្នុង-ក្រៅប្រទេសនានា ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរជាតិ ការស្នើសុំអាហារូបករណ៍ រៀបចំវគ្គបណ្តុះបណ្តាល ការស្វែងរកកៀរគរជំនួយ ព្រមទាំងការរៀបចំកម្មវិធីផ្សេងៗ។

## ៥-មុខងារអភិវឌ្ឍន៍ស្ថាប័ន

### ៥.១-សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា៖
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកុម្ភៈ និងទិសដៅការងារខែមីនា ឆ្នាំ២០២៦ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
  - បានអញ្ជើញប្រជុំជាមួយថ្នាក់ដឹកនាំគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ដឹកនាំដោយ **ឯកឧត្តម ឈិន កេតនា** ឧបនាយករដ្ឋមន្ត្រី អនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ព្រមទាំងមានការចូលរួមពីតំណាងក្រសួងព្រះបរមរាជវាំង ដើម្បីពិនិត្យពិភាក្សាត្រៀមរៀបចំព្រះរាជពិធីសម្ពោធអគារវិមានសាមគ្គីភាពនៃព្រឹទ្ធសភា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា និង
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការគ្រប់គ្រង ប្រើប្រាស់ និងសម្របសម្រួលរៀបចំពិធី និងកិច្ចប្រជុំនានា ក្នុងវិមានសាមគ្គីភាពនៃព្រឹទ្ធសភា ដើម្បីពិភាក្សា និងរៀបចំផែនការគ្រប់គ្រង ប្រើប្រាស់ និងថែទាំ ការពារសន្តិសុខ និងសណ្តាប់ធ្នាប់នៅបរិវេណអគារវិមានសាមគ្គីភាពនៃព្រឹទ្ធសភា។

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និង**ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញទទួលដំណើរ **សម្តេចមហាមន្ត្រី គុយ សុផល** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង និង**ឯកឧត្តម ឈិន កេតនា** ឧបនាយករដ្ឋមន្ត្រី អនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ តំណាងអង្គភាពពាក់ព័ន្ធចំនួន២លើក ដើម្បីពិនិត្យទីកន្លែងត្រៀមរៀបចំព្រះរាជពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារ "វិមានសាមគ្គីភាព" ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា។

- **ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញប្រជុំពិភាក្សាការងារស្តីពី កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ នៅសាលប្រជុំពិសេសខាងក្រោមវិមានព្រឹទ្ធសភា និង

- **ឯកឧត្តម ឌី បញ្ញា** អគ្គលេខាធិការរងព្រឹទ្ធសភា បានផ្តល់សៀវភៅ **១១១ចំណុច ប្រសាសន៍ណែនាំរបស់សម្តេចតេជោ** ជូនខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## ៤.២-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ

- បានស្នើសុំបុរេប្រទានថវិកា និងចុះប្រព័ន្ធFMIS សម្រាប់ការចំណាយទទួលទស្សនកិច្ចរបស់ប្រធានព្រឹទ្ធសភានៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម និងប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។
- បានបង្វែរប្រាក់បង់វិភាគទានហានិភ័យការងារ និងភាគទានថែទាំសុខភាព ជូនអង្គភាពបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកុម្ភៈ ឆ្នាំ២០២៦។
- បានបង្វែរប្រាក់បៀវត្ស ប្រាក់បំណាច់ ប្រចាំខែកុម្ភៈ ឆ្នាំ២០២៦ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិក សមាជិកាព្រឹទ្ធសភា សមាជិក សមាជិកាព្រឹទ្ធសភាចូលនិវត្តន៍ និងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និវត្តជន មន្ត្រីនគរបាលសន្តិសុខ ជំនួយការផ្ទាល់ អ្នកបើកបររថយន្ត តាមរយៈប្រព័ន្ធធនាគារអេស៊ីលីដា។
- បានបង្វែរប្រាក់ប្រមុខរដ្ឋស្តីទី ប្រាក់សង្គមកិច្ចថ្នាក់ដឹកនាំព្រឹទ្ធសភា ប្រាក់ឧបត្ថម្ភពិនិត្យ និងព្យាបាលជំងឺមន្ត្រីរាជការ ប្រាក់៧%នៃប្រាក់បៀវត្សមន្ត្រីរាជការបង់ចូលបេឡាសោធននិវត្តន៍ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងប្រាក់ឧបត្ថម្ភមូលនិធិសង្គមកិច្ចមន្ត្រីរាជការ ប្រចាំខែកុម្ភៈ ឆ្នាំ២០២៦ តាមរយៈប្រព័ន្ធធនាគារអេស៊ីលីដា។
- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១៥៧សំណើ ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗ ចំនួន១៥៦សំណើ។
- បានដោះស្រាយសំណើផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ ចំនួន៣៧សំណើ។
- បានថតចម្លងឯកសារ ចំនួន៤,០២០ច្បាប់ ប្រើប្រាស់ក្រដាសអស់ ចំនួន៣០,០១២សន្លឹក។
- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្ម នៅតាមបណ្តាភូមិភាគទាំង៨ ចំនួន៩៤លើក ស្មើនឹង២៤៣នាក់។
- បានរៀបចំបោសសម្អាត តុបតែងលម្អសាល ព្រមទាំងផ្តល់សេវាបម្រើភេសជ្ជៈ ក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន២៧លើក។
- បានទទួលលិខិតចូល ចំនួន៣៧៤ច្បាប់ និងបញ្ជូនលិខិតចេញទៅក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ចំនួន៣៣៦ច្បាប់។

- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៦១ច្បាប់ ស្មើនឹង៣២៨នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភា ចំនួន១០ច្បាប់។
- បានចុះសួរសុខទុក្ខនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៨នាក់។
- ការងារកែលម្អសួនច្បារ និងបរិស្ថានក្នុងបរិវេណព្រឹទ្ធសភា រួមមាន៖
    - បានតាំងលម្អផ្កាស្បៃរឿងម៉ាឡេស៊ី និងផ្កាម្លិះថ្ម ចំនួន៣៨០គុម្ព។
    - បានដាំដើមឫស្សី និងដើមជ្រៃ ចំនួន២៧គុម្ព។
    - បានគាស់ដើមជ្រៃដាក់ក្នុងផើងមកដាំនៅច្រកចេញ-ចូល P2 ចំនួន៤០គុម្ព។
    - បានកាត់តម្រឹមស្មៅ មែកឈើ និងផ្កានានា ចំនួន១២លើក។
    - បានបាញ់ថ្នាំសម្លាប់សត្វល្អិត និងស្មៅតាមសួនច្បារនានា និង
    - បានសម្អាតអនាម័យតាមអគារធ្វើការ និងក្នុងបរិវេណព្រឹទ្ធសភាជាប្រចាំ។
- បានបន្តសម្របសម្រួលការរៀបចំគូរប្លង់រចនាទេសភាពសួនច្បារស្រះត្រី និងសួនច្បារសាលពិសេសវិមានព្រឹទ្ធសភា។
- បានធ្វើបញ្ជីស្ថិតិមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យា ប្រចាំខែកុម្ភៈ ឆ្នាំ២០២៦ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖
    - មន្ត្រីរាជការក្របខ័ណ្ឌ ចំនួន៧២១នាក់ (ស្រី២៩១) ក្នុងនោះមន្ត្រីរាជការស្ថិតក្នុងភាពទំនេរដោយគ្មានបៀវត្ស ចំនួន១២នាក់, មន្ត្រីរាជការស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចំនួន៦នាក់, មន្ត្រីរាជការមានមុខតំណែងគ្រប់គ្រង ចំនួន៤៩១នាក់ និង
    - បុគ្គលិកជាប់កិច្ចសន្យា ចំនួន៩៧នាក់ (ស្រី៣៨នាក់)។
- បានធ្វើសេចក្តីសម្រេច ចំនួន៤ច្បាប់។
- បានធ្វើតារាងបញ្ជាក់ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ និងវិញ្ញាបនបត្របញ្ជាក់រយៈពេលបំពេញការងាររដ្ឋ ចំនួន៤ច្បាប់។
- បានធ្វើបញ្ជីរាយនាមមន្ត្រីរាជការស្នើសុំប្រាក់វិភាជន៍គ្រួសារ (ប្រពន្ធ-កូន) ប្រចាំខែកុម្ភៈ ឆ្នាំ២០២៦។
- បានរៀបចំបែបបទជូនទីប្រឹក្សាព្រឹទ្ធសភា ចំនួន១រូប ចូលរួមសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៅសាកលវិទ្យាល័យអាស៊ីអឺរ៉ុប។
- ការងារជួសជុលកែលម្អអគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ក្នុងបរិវេណវិមានព្រឹទ្ធសភា រួមមាន៖
    - បានជួសជុលបង្កាន់ដៃម៉ាប និងដំឡើងសសរអ៊ីណុក នៅអគារវិមានសាមគ្គីភាព។
    - បានជួសជុលដំបូលនៅប៉ុស្តិ៍យាមច្រកចេញ-ចូល P3 និងដំបូលស័ង្កសីបន្ទប់ទឹក នៅសាលសិក្ខាសាលាខាងជើង។
    - បានប្តូរកញ្ចក់ អូតូទ្វារ អូតូធំទ្វារអាលុយមីញ៉ូម ពិដាន នៅអគារក្រហម និងអគារ E។
    - បន្តសហការជាមួយសាលារាជធានីភ្នំពេញរៀបចំអាងរំដោះទឹកនៅប៉ែកខាងក្រោយព្រឹទ្ធសភា។
    - បានកាត់ទូដែកដាក់នៅបន្ទប់គ្រប់គ្រងកាម៉េរ៉ា នៅអគារវិមានសាមគ្គីភាព។

- បានបង្រួមសួន ពង្រីកផ្លូវ នៅច្រកចេញ-ចូល P2 និង
- បានលាបគំនូសចរាចរណ៍ ពីច្រកចេញ-ចូល P2 ដល់មុខអគារក្រហម។

- បានជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធអគារ បណ្តាញទឹក បណ្តាញអគ្គិសនី ត្រួតពិនិត្យជណ្តើរយន្ត កំចាត់សត្វកណ្តៀរ រៀបចំ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារិម ប្រមូលសម្ភារខូច បិទលេខកូដសម្ភារសារពើភ័ណ្ឌ និងបំពាក់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតក្នុងបរិវេណព្រឹទ្ធសភា ចំនួន៩៩គ្រឿង/លើក។
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា ប្រចាំខែកុម្ភៈ ឆ្នាំ២០២៦ ទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា។
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកុម្ភៈ ឆ្នាំ២០២៦ ព្រមទាំងបានផ្សព្វផ្សាយលើគេហទំព័រព្រឹទ្ធសភា និងផ្ញើជូនក្រសួង ស្ថាប័នពាក់ព័ន្ធនានា និង
- បានធ្វើបទបង្ហាញ និងរបាយការណ៍ស្តីពី ការប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកុម្ភៈ ឆ្នាំ២០២៦។

## ៥.៣-ការងារសេវាច្បាប់៖

- បានទទួលអនុក្រឹត្យ សេចក្តីសម្រេច ប្រកាស សេចក្តីជូនដំណឹង និងលិខិតផ្សេងៗ ចំនួន១៨ច្បាប់ ពីក្រសួង និងស្ថាប័ននានា។
- បានធ្វើកំណត់ហេតុពិស្តារ និងកំណត់ហេតុសង្ខេបនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ចំនួន៦លើក។
- បានផ្តល់សេវារដ្ឋបាល បច្ចេកទេស ព័ត៌មាន ពិធីការ ទំនាក់ទំនងការងារ ធ្វើរបាយការណ៍ និងរៀបចំកំណត់បង្ហាញ ឯកសារផ្សេងៗ ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាគណៈកម្មការទាំង១០ និងក្រុមនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ព្រមទាំងក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន២៨៤លើក និង
- បានផ្ទៀងផ្ទាត់ សម្របសម្រួលការបញ្ជូនឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល តាមរបប២ឆ្នាំចប់អាណត្តិ ឬលាលែងពីមុខតំណែង ចំនួន២៨នាក់។

## ៥.៤-ការងារស្រាវជ្រាវ៖

- បានសិក្សាស្រាវជ្រាវ រៀបចំឯកសារជំនួយស្មារតី និងបានធ្វើបទបង្ហាញលើប្រធានបទស្តីពី ការគាំទ្រមរតកសន្តិភាព ស្ថិរភាពនៅកម្ពុជា និងគំនិតផ្តួចផ្តើម សម្រាប់ភាពមិនចុះចាញ់តាមរយៈដោយប្រើវិធីសាស្ត្រផ្អែកលើការត្រិះរិះពិចារណា ជូនគណៈកម្មការទី៧ព្រឹទ្ធសភា។
- បានសិក្សាស្រាវជ្រាវអំពី៖
    - បទពិសោធន៍កម្ពុជាក្នុងការដោះមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ និងវិជ្ជភាពសេដ្ឋកិច្ច និងការកសាងជីវភាពប្រជាជនតាមតំបន់ព្រំដែន។

- សេដ្ឋកិច្ចតាមបណ្ដោយព្រំដែន៖ ដោយផ្ដោតលើឯកសារពាក់ព័ន្ធនឹងការបង្កើតតំបន់សេដ្ឋកិច្ចពិសេស។
- ការលើកកម្ពស់សុខុមាលភាព និងបង្កើនផលិតភាពជីកសិកម្មនៅតំបន់ជាប់ព្រំដែន។
- ផ្នែកថវិការដ្ឋ និងថវិកាថ្នាក់ក្រោមជាតិ តុល្យការថវិកា ការខ្ចី និងស្ថានភាពបំណុលសាធារណៈ និងហានិភ័យសារពើពន្ធ។
- ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច។
- ការប្រៀបធៀបបរិបទប្រទេសនៅក្នុងតំបន់អាស៊ាន។
- ការរៀបចំប្រមូលទិន្នន័យថវិកាមូលនិធិ ថ្នាក់ឃុំ-សង្កាត់ ឆ្នាំ២០២៦ និង
- របាយការណ៍ និន្នាការសេដ្ឋកិច្ច-សង្គមប្រចាំខែរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

- បានសិក្សាស្រាវជ្រាវ និងតាមដាន៖
  - វឌ្ឍនភាពនៃការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយពាក់ព័ន្ធតាមវិស័យនានា និង
  - របាយការណ៍របស់ធនាគារជាតិនៃកម្ពុជា និងព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា។
- បានតាមដាន និងចងក្រងឯកសារគោលនយោបាយជាតិស្តីពី ក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ។
- បន្តចងក្រងទិន្នន័យលិខិតបទដ្ឋានគតិយុត្តតាមវិស័យរបស់គណៈកម្មការនានា។
- បានសង្ខេបលទ្ធផលនៃការប្រមូលចំណូលពន្ធគយប្រចាំឆ្នាំ២០២៥។
- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច ប្រចាំសប្តាហ៍នៃខែកុម្ភៈ ឆ្នាំ២០២៦ ចំនួន៤ច្បាប់។
- បានបកប្រែ និងសង្ខេបព័ត៌មានសភាបញ្ចូលក្នុងសម្រង់សង្ខេបព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ចំនួន២០២ព័ត៌មាន និង
- បានបញ្ចូលព័ត៌មាន និងចាត់ថ្នាក់ទៅតាមវិស័យច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (រាជកិច្ចពីលេខ ១-៥ ឆ្នាំ២០២៥)។

**៩.៥-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖**

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន២៣លើក។
- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងបណ្ដាញសង្គម ចំនួន១,៦៦៩លើក។
- បានបញ្ចូល និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភា ចំនួន២៨១លើក។
- បានអញ្ជើញអ្នកសារព័ត៌មាន ចូលយកព័ត៌មានព្រឹទ្ធសភា និងពិធីផ្សេងៗ ចំនួន៣លើក។
- បានតាំងពិព័រណ៍រូបភាពសកម្មភាពរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា នៅខាងមុខព្រឹទ្ធសភា ចំនួន៩លើក។
- បានរៀបចំផលិតទស្សនាវដ្ដីព្រឹទ្ធសភា ប្រចាំខែកុម្ភៈ ឆ្នាំ២០២៦។

- បានសិក្សាស្រាវជ្រាវ ចងក្រងព្រឹត្តិបត្រស្ដីពី បច្ចេកវិទ្យាព័ត៌មាន ចំនួន២៤ចំណងជើង។
- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធណេតវើក អ៊ីនធឺណែត ពង្រឹងពង្រីកការផ្គត់ផ្គង់ ថែទាំ និងជួសជុលឧបករណ៍ សម្ភារ បរិក្ខារបច្ចេកទេស ព្រមទាំងដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មាន ចំនួន១៤០គ្រឿង/លើក។
- បានរៀបចំប្រព័ន្ធស្ទូឌីយ៉ូ ប្រព័ន្ធកាមេរ៉ា ប្រព័ន្ធប្រជុំនិម្មិត ព្រមទាំងបានរចនាផ្ទាំង Backdrop Background និងបញ្ចាំងផ្ទាំង LED ក្នុងកិច្ចប្រជុំ ជំនួបសម្ដែងការគួរសម និងពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ និងកម្មវិធីផ្សេងៗ ចំនួន៥៤លើក។
- បានទទួលឯកសារ ព្រឹត្តិបត្រ សៀវភៅច្បាប់ និងសៀវភៅជំនាញផ្សេងៗ ចំនួន៣២ក្បាល ព្រមទាំងបានបោះត្រាសៀវភៅ ដាក់លេខកូដសៀវភៅ អ៊ុតក្របសៀវភៅ ជួសជុលសៀវភៅ បិទប័ណ្ណខ្ចី និងសងសៀវភៅ ចំនួន៣០២ក្បាល។
- បានរៀបចំបញ្ចូលឯកសារ សៀវភៅជា E-Book លើផ្នែកច្បាប់ និងសៀវភៅដែលទាញចេញពីគេហទំព័របស់បណ្ណាល័យនានា ក្នុងគេហទំព័រ www.elibrary.senate.gov.kh ចំនួន១០ក្បាល និង
- បានទទួលឯកសារពីអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងបានរៀបចំចាត់ថែងរក្សាទុកឯកសារនៅបណ្ណសារដ្ឋាន ដោយបាន៖
  - រៀបចំឯកសាររបស់នាយកដ្ឋានរដ្ឋបាល ឆ្នាំ២០០១-២០០៤ ចំនួន១៣៦សំណុំលិខិត និង
  - ត្រួតពិនិត្យបញ្ចូលមាតិកាលិខិត និងមាតិកាសំណុំលិខិតទៅក្នុងប្រព័ន្ធកុំព្យូទ័រ ចំនួន៣៤សំណុំ។

### ៩.៦-ការងារពិធីការ និងទំនាក់ទំនងអន្តរជាតិ៖

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ ជំនួបសម្ដែងការគួរសម ពិភាក្សាការងារ និងពិធីផ្សេងៗ ចំនួន៣០លើក។
- បានរៀបចំសារលិខិតជូនពរ លិខិតថ្លែងអំណរព្រះគុណ និងលិខិតរំលែកទុក្ខ របស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៦លិខិត។
- បានរៀបចំកំណត់ទូត និងឯកសារផ្សេងៗ ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៣ច្បាប់/លើក។
- បានតាមដាន និងចងក្រងសេចក្ដីប្រកាសព័ត៌មាន និងសេចក្ដីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន៩ច្បាប់ និង
- បានរៀបចំបែបបទស្នើសុំលិខិតឆ្លងដែនការទូតជូនសមាជិក សមាជិកាព្រឹទ្ធសភា និងសហព័ន្ធ ចំនួន៥រូប។

### ៩.៧-ការងារអគ្គាធិការដ្ឋាន៖

- បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្ដល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកុម្ភៈ ឆ្នាំ២០២៦ ចំនួន២២លើក។

- បានប្រមូល និងរៀបចំរបាយការណ៍ជាមួយនាយកដ្ឋានផែនការ និងសរុប នាយកដ្ឋានគ្រប់គ្រងបុគ្គលិក នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងបណ្ណសារដ្ឋានស្តីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានា របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានរៀបចំរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវា ប្រចាំខែកុម្ភៈ ឆ្នាំ២០២៦។
- បានចុះត្រួតពិនិត្យវត្តមានជាក់ស្តែងតាមនាយកដ្ឋាននានា ប្រចាំខែកុម្ភៈ ឆ្នាំ២០២៦ ចំនួន២លើក ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមាន ដែលនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមាន ប្រចាំថ្ងៃ ចំនួន៤៤លើក ប្រចាំសប្តាហ៍ចំនួន៤លើក និងប្រចាំខែកុម្ភៈ ឆ្នាំ២០២៦ ដែលគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារតាមអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា និង
- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីរាជការតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## II-ទិសដៅការងារខែមីនា ឆ្នាំ២០២៦

### ១- មុខងារនីតិកម្ម

- ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។

### ២-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយក្រសួង ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ និងចុះបេសកកម្ម ដើម្បីតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា របស់រាជរដ្ឋាភិបាលក្នុងរយៈពេលវិស្សមកាល៣ខែ ចាប់ពីថ្ងៃទី៧ ខែមករា ដល់ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៦ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។

### ៣- មុខងារតំណាង

- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា៖
    - អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ពិភាក្សាការងារជាមួយអាជ្ញាធរដែនដី ពិនិត្យវឌ្ឍនភាពនៃការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ និង
    - អញ្ជើញចូលរួមសិក្ខាសាលា វេទិកា កិច្ចប្រជុំនានា និងពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។
- ត្រៀមផ្តល់សេវាជូនក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ ចុះជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំស្រុក ក្រុមប្រឹក្សាឃុំ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាល នៅខេត្តបន្ទាយមានជ័យ។

- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំក្នុងពិធីជួបសំណេះសំណាលជាមួយគណៈប្រតិភូជាតិនារី ក្នុងឱកាសទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៦។
- ត្រៀមរៀបចំពិធីអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ខួបលើកទី១១៥ ឆ្នាំ២០២៦។
- ត្រៀមបញ្ជូនសារលិខិតជូនពរ គោរពជូនថ្នាក់ដឹកនាំ សមាជិក និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០។
- ត្រៀមរៀបចំពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ និង
- ត្រៀមទទួលដំណើរទស្សនកិច្ចរបស់សាធារណជន សិស្ស និងនិស្សិត ដើម្បីសិក្សាឈ្វេងយល់អំពីរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- ត្រៀមផ្តល់សេវាការងារការទូតសភា ការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកា កម្មវិធីជំនួប កម្មវិធីផ្លូវការ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា។
- ត្រៀមរៀបចំដំណើរទស្សនកិច្ចផ្លូវការរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ទៅកាន់សហគមន៍អឺរ៉ុប។
- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមមហាសន្និបាត IPU លើកទី១៥២ នៅសាធារណរដ្ឋតួកគីយ៉េ។
- ត្រៀមធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទប្រធានសភានៃអន្តរសភា(ISC) លើកទី២ នៅរាជធានីភ្នំពេញ។
- ត្រៀមចូលរួមសហការរៀបចំកិច្ចប្រជុំកំពូលក្រុមប្រទេសនិយាយភាសាបារាំង ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ នាខែវិច្ឆិកា ឆ្នាំ២០២៦ នៅរាជធានីភ្នំពេញ និង
- បន្តត្រៀមស្រាវជ្រាវ បកប្រែ និងរៀបចំឯកសារជំនួយស្មារតី សុន្ទរកថាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបជាមួយភ្ញៀវអន្តរជាតិ ជំនួបសវនាការ កិច្ចប្រជុំ និងទស្សនកិច្ចនានា។

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

- ត្រៀមរៀបចំពិធីសម្ពោធជាផ្លូវការអគារថ្មីនៃព្រឹទ្ធសភា។
- ត្រៀមបើកវគ្គបណ្តុះបណ្តាលស្តីពី វគ្គទំនាក់ទំនងអន្តរជាតិ វគ្គសរសេររបាយការណ៍ និងកំណត់ហេតុប្រជុំ។
- បន្តប្រជុំគណៈកម្មការ ដើម្បីរៀបចំអនុគណៈកម្មការគ្រប់គ្រងអគារ និងបទបញ្ជាផ្ទៃក្នុងប្រើប្រាស់អគារវិមានសាមគ្គីភាព។
- ការគិតគូររៀបចំ និងប្រើប្រាស់ចំណតយានយន្តសម្រាប់វិមានសាមគ្គីភាព និងនៅបរិវេណវិមានព្រឹទ្ធសភា។
- បន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានារួមមាន បន្តជំរុញការងារសាងសង់អាងរំដោះទឹក ការសាងសង់អគារថ្មី ការជួសជុល ថែទាំ កែលម្អបរិស្ថាន អនាម័យ សួនច្បារ ប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹក ប្រព័ន្ធលូ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា ប្រកបដោយសុខសុវត្ថិភាព និង

- បន្តផ្តល់សេវាផ្គត់ផ្គង់សម្ភារ ថវិកា មធ្យោបាយដឹកជញ្ជូន ទំនាក់ទំនងជាមួយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងសេវាសំខាន់ៗផ្សេងទៀតជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនឱ្យបានទាន់ពេលវេលា និងល្អប្រសើរ។

## III-សេចក្ដីសន្និដ្ឋាន

ក្នុងខែកុម្ភៈ ឆ្នាំ២០២៦ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអនុវត្តភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម និងមានប្រសិទ្ធភាព លើមុខងារសំខាន់ៗ រួមមាន ការផ្តល់សេវាលើមុខងារតាមដានការអនុវត្តច្បាប់ មុខងារតំណាង មុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ និងមុខងារអភិវឌ្ឍន៍ស្ថាប័ន។ តាមរយៈការចុះបេសកកម្មតាមមូលដ្ឋាន កិច្ចប្រជុំ ពិភាក្សាការងារ និងសកម្មភាពការទូតសភា បានចូលរួមចំណែកក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ ការផ្តល់សេវាសាធារណៈ និងការពង្រឹងទំនាក់ទំនងជាតិ និងអន្តរជាតិ។

លទ្ធផលការងារដែលសម្រេចបាន បានបង្ហាញពីការសហការល្អរវាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងការគាំទ្រដល់ការបំពេញតួនាទីរបស់ព្រឹទ្ធសភា ឱ្យកាន់តែមានប្រសិទ្ធភាព និងឆ្លើយតបតាមតម្រូវការអភិវឌ្ឍន៍សង្គមជាតិ។

ជាមួយគ្នានេះ ទិសដៅការងារសម្រាប់ខែមីនា ឆ្នាំ២០២៦ ត្រូវបានកំណត់យ៉ាងច្បាស់ ដោយផ្តោតលើការបន្តពង្រឹងការតាមដានការអនុវត្តច្បាប់ ការចូលរួមជាមួយប្រជាពលរដ្ឋ និងអង្គបោះឆ្នោតក្នុងអំឡុងពេលវិស្សមកាល ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការអភិវឌ្ឍសមត្ថភាពស្ថាប័ន ដើម្បីធានាថាការបំពេញភារកិច្ចរបស់ព្រឹទ្ធសភា បន្តប្រព្រឹត្តទៅដោយប្រសិទ្ធភាព តម្លាភាព និងចីរភាព។

ថ្ងៃ អង្គារ ១១ រោច ខែ ពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៦

**អគ្គលេខាធិការ**

**ឡាយ សំគុល**